# កិច្ចសំភាសន៍របស់លោកយាយឈ្មោះ ហ៊ាម បក្ស

កៈ អ្នកសំភាសន៍ឈ្មោះ ហេង សុជីវី ខៈ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះ ហ៊ាម បក្ស

កៈ ចាសជាដំបូងសូមជំរាបសួរម៉ា!

ខៈ ចាសកូន! ជំរាបសួរ!

កៈ ចាសម៉ា! ថ្ងៃនេះខ្ញុំមានល្អមែនទែនដែលបានមកសំភាសន៍ម៉ាផ្ទាល់!

ខៈ ចាសកូន!

កៈ ហើយចៅធ្វើការនៅគំរោងស្ម័គ្រចិត្តនៅសាលា BYU ហាវៃនៅខាងសហរដ្ឋអាមេរិច....

ខៈ ចាសៗ....

កៈ
ហើយខាងគំរោងសាលាមួយនឹងគេតម្រូវអោយធ្វើការសំភាសន៍ប្រជាជនកម្ពុជាដែលពួកគាត់មានវ័យចាប់ពី៣៥ឆ្នាំឡើងអំពីពង្សប្រវត្តិរបស់ពួកគាត់ហើយនឹងជីវិតរបស់ពួកគាត់តាំងពីមុនរហូតមកដល់ឥលូវនឹងថាគាត់ធ្លាប់បានឆ្លងកាត់ជីវិតអីគេខ្លះដើម្បីនឹងគេរក្សាទុកសំលេងរបស់គាត់ទុកអោយក្មេងជំនាន់ក្រោយគេបានស្តាប់ដែរណាស់ម៉ា!
អញ្ចឹងតើម៉ាអឺ...អនុញ្ញាណអោយខ្ញុំក្នុងការថតសំលេងរបស់ម៉ាហើយនឹងយកសំលេងរបស់ម៉ាយកទៅផុសនៅក្នុងវេបសាយដើម្បីធ្វើការចងក្រងដើម្បីអោយកូនចៅជំនាន់ក្រោយគេអាចចូលទៅក្នុងវេបសាយនឹងហើយស្តាប់សំលេងរបស់ម៉ាដែរឬទេ?

ខៈ ចាសៗ!

កៈ ចាសអរគុណម៉ា! អញ្ចឹងជាដំបូងនៃការសំភាសន៍នឹងគឺធ្វើឡើងនៅក្នុងថ្ងៃនេះគឺក្នុងថ្ងៃទី ១៩ខែ០៧ ឆ្នាំ២០១៨!

ខៈ ចាស!

កៈ ហើយចៅសូមសួរឈ្មោះរបស់ម៉ាតើម៉ាមានឈ្មោះអីដែរម៉ា?

ខៈ ខ្ញុំឈ្មោះ ហ៊ាម បក្ស!

កៈ ចាសម៉ា! ហើយតើឈ្មោះនឹងត្រូវជាមួយនឹងអត្តសញ្ញាណប័ណ្ណរបស់ម៉ាដែរឬទេម៉ា?

ខៈ ត្រូវទាំងអស់អត់មានកែប្រែនោះទេកូន!

កៈ ចាសម៉ា! ហើយចុះម៉ាមានឈ្មោះហៅក្រៅដែរឬទេ?

ខៈ អត់មានទេកូន មានឈ្មោះតែមួយនឹង!

កៈ ចាសម៉ា! ហើយចុះឈ្មោះនឹងអ្នកណាគេជាអ្នកដាក់អោយម៉ាដែរម៉ា?

ខៈ ម្ដាយរបស់ខ្ញុំ!

កៈ ចាសម៉ា! ហើយគាត់ដាក់ឈ្មោះនឹងអោយម៉ាតើគាត់មានបានប្រាប់ម៉ាថាឈ្មោះនឹងមានអត្ថន័យយ៉ាងណាទេម៉ា?

ខៈ មិនដឹងយ៉ាងម៉េចទេ (មានសំលេងរំខានពីខាងក្រៅ) ដឹងតែថាគាត់ដាក់អោយអញ្ចឹងម៉ងម៉ាមិនបានដឹងដែរនឹងកូន គាត់គ្រាន់តែដាក់អោយអញ្ចឹងម៉ង!

កៈ អឹម! អ្នកម្ដាយរបស់ម៉ាគាត់មានឈ្មោះអីដែរម៉ា?

ខៈ គាត់ឈ្មោះ ឡាយ តូច!

កៈ ចុះលោកឪពុករបស់ម៉ាវិញ?

ខៈ លោកឪពុកម៉ាឈ្មោះ អឺវ ហ៊ម!

គៈ ខ្ញៅដូងចំហ៊ុយមានរសជាតិឈ្ញុយឆ្ងាញ់ (សំលេងរំខានពីខាងក្រៅ)!

កៈ ចាសម៉ា! ហើយចុះពួកគាត់ទាំងពីរនាក់នឹងសព្វថ្ងៃមានព្រះជន្មនៅដែរឬទេម៉ា?

ខៈ គាត់ខូចបាត់ហើយយូរដែរហើយ!

គៈ ខ្ញៅដូងចំហ៊ុយមានរសជាតិឈ្ញុយឆ្ងាញ់ (សំលេងរំខានពីខាងក្រៅ)!

កៈ គាត់ខូចហើយន៏ម៉ា?

ខៈ ចាសកូន! គាត់ខូចតាំងពីសង្គមម្លេះកូន!

កៈ អឺម....តាំងពីម៉ាមានអាយុប៉ុន្មានឆ្នាំដែរម៉ា? (មានសំលេងរំខានពីខាងក្រៅ)!

ខៈ តាំងពីខ្ញុំមានគ្រួសារមានអីហើយអស់ទៅកូនណាស់!

កៈ ចាសម៉ា!

ខៈ
បែកអាពតទៅនឹងគេជំលៀសទៅនឹងគាត់ខូចនៅនឹងអាពតហើយម្តាយក៏ស្លាប់នៅក្នុងជំននាន់អាពតនឹងដែរ!

កៈ អឺម!

ខៈ ចាសកូន! បែកគ្នាណាស់កូនណាស់!

កៈ ចាសម៉ា!

ខៈ គេជំលៀសយើងទៅ.....

កៈ ចុះឥលូវនឹងម៉ាមានអាយុប៉ុន្មានឆ្នាំហើយ?

ខៈ ខ្ញុំអាយុ៧៥ឆ្នាំហើយ!

កៈ ម៉ាកើតនៅក្នុងថ្ងៃខែឆ្នាំកំណើតណាដែរ?

ខៈ ខ្ញុំអត់ចាំសោះកូន(មានសំលេងរំខានពីខាងក្រៅ!

កៈ អឺម!

ខៈ អត់ចាំទេកូន!

កៈ ចុះម៉ាមានអត្តសណ្ណាណប័ណ្ណដែរឬទេ?

ខៈ អត្តសញ្ញាណប័ណ្ណមានប៉ុន្តែនៅឯផ្ទះឯណោះកូន!

កៈ អឺម! (មានសំលេងរំខានពីខាងក្រៅ) ចុះម៉ាមាននៅចាំថ្ងៃខែឆ្នាំកំណើតចន្ទគតិសុរិយគតិរបស់ខ្មែរយើងដែរឬទេម៉ា?

ខៈ អត់ចាំទេកូន ព្រោះអត់ចេះអក្សរផង!

កៈ អូ....អញ្ចឹងអឺ...ឆ្នាំដូចជាឆ្នាំសត្វណាស់ម៉ាជូត ឆ្លូវ.....

ខ៖ ខ្ញុំឆ្នាំរក!

ក៖ ចាសម៉ា!

ខ៖ ដឹងតែថាម៉ែពេលដែលអត់ពីគាត់ទៅនៃ...មឹងមាអីគេប្រាប់ណាស់កូនណាស់នឹងហើយខ្ញុំនៅចាំ!

ក៖ ចាសម៉ា! នៅ.....

ខ៖ ប៉ុន្តែឪពុករបស់ខ្ញុំគាត់ស្លាប់នៅជំនាន់អពតម្តាយក៏ស្លាប់នៅក្នុងជំនាន់អាពតគេជំលៀសទៅយើងក៏បែកគ្នាណាស់កូនណាស់!

ក៖ ចាសម៉ា!

ខ៖ ចាសកូន!

ក៖ ចុះម៉ាមានបងប្អូនប៉ុន្មាននាក់ដែរ?

ខ៖ បងប្អូនរបស់ម៉ាច្រើនណាស់ប្រាំបួនឯណោះប៉ុន្តែអស់ហើយនេះនៅសល់តែម្នាក់ឯងរាល់ថ្ងៃនឹងណាស់កូន!

ក៖ អឺម! សូមទោសណាស់ម៉ាដែលបានលឺអញ្ចឹងណាស់ម៉ា!

ខ៖ ចាសកូន!

ក៖ ចុះបងប្អូនរបស់ម៉ាពួកគាត់មានឈ្មោះអីខ្លះដែរ?

ខ៖ ឈ្មោះអឺ....បងរបស់គេបង្អស់ឈ្មោះ គុម្ព ស្រីទេណាស់កូនណាស់ដល់តែបន្ទប់មកនឹងឈ្មោះ ញ៉ូវ អ័....ឈ្មោះធួក ស្រីដែរ!

ក៖ ចាស!

ខ៖ ដល់បន្ទាប់មកទៀតបានឈ្មោះ ញ៉ូវ ដលបន្ទាប់មកទៀតបានឈ្មោះ ចឹម ចឹមហើយបានឈ្មោះសុខ ដល់សុខហើយឈ្មោះឈិន នឹងពៅគេហើយណាស់!

ក៖ ចាសម៉ា!

ខ៖ ហើយខ្ញុំឈ្មោះបក្ស ហ៊ម បក្ស ចាស!

កៈ ចាសម៉ា! អញ្ចឹងម៉ាជាកូនពៅគេហ៍ម៉ា?

ខៈ អត់ទេមិនមែនទេ! (មានសំលេងរំខានពីខាងក្រៅ) កូនពៅគេប្អូនអាប្រុសនោះឈ្មោះឈិន នោះណាស់!

កៈ ចាសម៉ា!

ខៈ អឺរ ឈិន ចាសនឹងប្អូនពៅគេបង្អស់ ចាស!

កៈ ចាសម៉ា! បងប្អូនរបស់ម៉ាមានស្រីប៉ុន្មាននាក់ប្រុសប៉ុន្មាននាក់ដែរម៉ា?

ខៈ ប្រុសតែម្នាក់ទេ ស្រីនឹងប្រាំបីនាក់(មានសំលេងរំខានពីខាងក្រៅ)!

កៈ ចាសម៉ា!

ខៈ ចាសកូន! ប៉ុន្តែស្លាប់អស់ហើយកូនអើយ!

កៈ ចាសម៉ាសោកស្តាយមែនទែនណាស់ម៉ា! ហើយកាលនឹងម៉េចបានជាពួកគាត់ស្លាប់ដែរម៉ា?(មានសំលេងរំខានពីខាងក្រៅ)!

ខៈ ជំងឺផង ស្លាប់ពីសង្គមនឹងផង (មានសំលេងរំខានពីខាងក្រៅ) ស្លាប់នៅពេលដែលគេជំលៀសទៅផងណាស់កូនណាស់ ស្លាប់ពេលដែលជំលៀសទៅនឹងវា....តែបីអ្នកទេប្ងូននាក់តាំងអាប្រុសហើយទាំងម្តាយរបស់ខ្ញុំទៅបែកគ្នាណាស់កូនណាស់ ខ្ញុំជាប់ខាងឪពុកហើយបងប្អូននឹងនៅជាប់ខាងម្តាយទៅព្រោះនៅពេលជំលៀសទៅគេចូលមកពីខាងណាគេអោយយើងចេញទៅខាងនឹងណាស់កូនណាស់ហើយគេចូលៗគ្រប់ច្រកណាស់ដូចថាផ្ទះរបស់អ៊ុំគេចូលមកពីលិចអញ្ចឹងទៅគេអោយអ៊ុំនឹងទៅតាមស្តាតចាសអញ្ចឹងទៅណាស់ហើយគាត់ៗគេជំលៀសគាត់អោយទៅបាត់ដំបងអញ្ចឹងទៅណាស់ (មានសំលេងរំខានពីខាងក្រៅ) ដល់ហើយនៅបែកគ្នាទៅគាត់ទៅនៅទៅលេងជាមួយកូនអីអញ្ចឹងទៅណាស់កូនណាស់ទទួលថៃដន្យវាអញ្ចឹងយើងទៅធ្វើម៉េច? បែកគ្នាទាំងអស់នឹងទៅ (មានសំលេងរំខានពីខាងក្រៅ) អត់បាននៅជុំគ្នាទេ ហើយដល់អញ្ចឹងទៅអ៊ុំក្រោយពីសង្គមមកនឹងមកអ៊ុំលក់ត្រីទេណាស់កូនណាស់!

កៈ អឺម!

ខ៖ ចាសលក់ផ្សារទីមួយយើងនៅនឹងទួលគោកនេះ ដល់តែពេលបែកអាពតអញ្ចឹងទៅក៏អុំទៅជំលៀសអោយទៅតាមគេតាមឯងអញ្ចឹងគេថាអោយចេញតែបីថ្ងៃទេណាស់កូនណាស់
ហើយទៅបីថ្ងៃចេញរហូតដល់ទៅបីឆ្នាំជាងបានៗមកវិញណាស់!

ក៖ ចាសម៉ា! ហើយចុះកាលនឹងម៉ាមានយកអឺ....របស់របរទៅតាមខ្លួនដែរទេ?

ខ៖ អត់បានអីទេកូនអត់បានទេ បានតែខោអាវបន្តិចបន្តួចហើយនឹងម្ហូបដូចថារបស់ហូបចុកអីអញ្ចឹងទៅណាស់ហើយអង្ករនឹងក៏អត់បានដាក់ទៅដែរព្រោះគេថាអោយទៅតែបីថ្ងៃណាស់កូនណាស់!

ក៖ ចាសម៉ា!

ខ៖ យកតែលុយទៅជាប់នឹងខ្លួនទៅទេណាស់!

ក៖ ទ្រព្យសម្បត្តិអី.....

ខ៖ ចាស....អូ! អត់មានយកទៅបាននោះទេអត់មានបានយកអីទៅរួចទេបានតែខោអាវបន្តិចហើយនឹងមាសប្រាក់បន្តិចដាក់ជាប់នឹងខ្លួនទៅទេណាស់កូនណាស់
ស្រាប់តែទៅដល់ព្រៃកញ្ចៅគេលែងចាយលុយទៅទៀត!

ក៖ អឹម!

ខ៖ អោយតែឃើញយើងចាយលុយគេចាប់ដូរហើយណាស់កូនណាស់! ចាស គេដូរយើងអត់មានអីដូរកូនអត់មានអីដូរចេះតែទៅៗសំណាក់នៅខាងក្តីរការកោងឯណោះខាងរកាកោងនឹង
ហើយទៅនឹងបានប្រហែលជាកន្លះខែៗគេជំលៀសយើងអោយមកវិញគេអោយយើងមកធ្វើការវិញណាស់កូនណាស់វាហៅមកវិញណាស់គេហៅមកវិញអោយយើងធ្វើការព្រោះគ្រួសាររបស់អុំគាត់ខាងធ្វើការខាងរទេះភ្លើងណាស់កូនណាស់ ខាងទូរណាស់កូនណាស់!

ក៖ ចាសម៉ា!

ខ៖ ចាសគេអោយមកធ្វើកាវិញក៏ត្រឡប់មកវិញត្រឡប់មកវិញទៅក៏គាត់មកធ្វើការងាររបស់គាត់វិ

ញទៅហើយទៅយើងប្រពន្ធនឹងដូចថាកងចល័តអីអញ្ចឹងទៅណាស់កូនណាស់ ដើរធ្វើការដាំបន្លែដាំអីអញ្ចឹងទៅណាស់កូនណាស់ ហើយគ្រួសារគាត់នៅធ្វើការងារនៅនឹងរោងចក្រទៅហើយពេលណានេះទៅគាត់ទៅលើកដី លើកអីអញ្ចឹងដែរតាមតែគេប្រើអញ្ចឹងទៅណាស់កូនតាមតែទិសដែលគេបានដាក់អោយយើង ណាស់!

ក៖ ចាសម៉ា!

ខ៖ ហើយអ៊ីក៏ទៅអញ្ចឹងដែរ ជូនណាទៅជញ្ជូនដីនៅវត្តសង្រ្គមាសឯណោះ ជញ្ជូនយកទៅដាក់ធ្វើជាផ្លូវណាស់កូនណាស់កាប់ធ្វើផ្លូវណាស់នឹងហើយ ដល់ពេលតែបែកពីអញ្ចឹងទៅមានថ្ងៃមួយនោះគេថា នែ....ពួកអាមេរិចចូលៗមកភ្នំពេញហើយគេអោយយើងជំលៀសទៅដំណក់ណាស់កូនណាស់ ព្រោះទូររទេះភ្លើងគេមកឈប់នៅនឹងមុខនឹងណាស់ក៏នាំគ្នាឡើងអ្នកមានគ្រួសារអ្នកដែលនៅ នឹងក្នុងនឹងណាស់ក៏នាំគ្នាឡើងទូររទេះភ្លើងទៅដល់ៗតំណាក់គេអោយគេយើងចុះសំរាកអញ្ចឹង ទៅណាស់កូនណាស់ ដល់តែយូរទៅអញ្ចឹងទៅគេចាប់អោយយើងដើរជំលៀសដើរនឹង ដើរទៅដល់ភូមិល្អួងឯណោះ!

ក៖ អូ....

ខ៖ ភូមិល្អួងនៅខាងពោធិសាត់ណាស់កូនណាស់នឹងហើយដើរទៅដល់នឹងទៅ នៅក្នុងភូមិល្អួងនឹងបានប៉ុន្មានទេគេជំលៀសយើងទៅទៀតគេអោយយើងទៅនៅនែ....ឯខាង អូរត្រជាក់ចិត្ត(មានសំលេងរំខានពីខាងក្រៅ) មិនដឹងថានៅឯណានោះទេណាស់កូនណាស់ទៅនៅ ឯខាងអូរត្រជាក់ចិត្តទៅនឹងបានប៉ុន្មានខែបានគេអោយទៅនៅឯទួលផ្អចទៀតនៅឯទួលផ្អចនឹ ងគេអោយយើងទៅកាប់ដីដំបូកនឹងយកមកដាក់ស្រែ!

ក៖ អឹម!

ខ៖ ចេះតែរែកទៅណាស់កូនណាស់នឹងហើយធ្វើទៅ គ្នាប៉ុន្មាន២០ទៅ៣០គ្រួសារអញ្ចឹងទៅគេចែកផ្នែកគ្នាអញ្ចឹងទៅណាស់ព្រោះមួយរទេះភ្លើងនឹង ទៅបែកៗគ្នាអស់ហើយកូនអ្នកណាទៅខាងណាទៅអ្នកណាទៅខាងណាទៅ ស្រេចតែនឹងទិសរបស់គេដែលចាត់តាំងយើងទៅណាស់នឹងហើយបែកគ្នាអញ្ចឹងទៅៗនៅនែ.. ..ទួលផ្អចនឹងបានទាល់តែរហូតនឹងបែកដល់តែបែកពីទួលផ្អចនឹងហើយបានខ្ញុំរកផ្លូវវិលត្រឡ

ប់មកភ្នំវិញណាស់កូនណាស់
ដល់អញ្ចឹងអ៊ុំនៅមានលុយតិចតួចទៅមានមាសតិចតួចទៅគេយកក្នុងមួយម្នាក់នឹងមួយជីដល់អញ្ចឹងហើយនាំកូនទៅ អញ្ជើញទៅកូនលោកនៅខាងក្នុង(និយាយជាមួយអ្នកផ្សេង) នែ....ទៅទួលផ្អូចនឹងគេអោយទៅកាប់ដំបូកដីដំបូកណាស់កូនណាស់!

ក៖ ចាសម៉ា!

ខ៖ កាប់ដីដំបូកនឹងយកមកដាក់នៅនឹងកណ្តាលស្រែគេអោយយើងធ្វើនឹងធ្វើស្រែក៏បានចេះតែធ្វើៗទៅចៅអើយដល់ពេលមានថ្ងៃមួយនោះទៅដងទឹកដងទឹកអណ្តូងផ្លូវឆ្ងាយណាស់កូនណាស់ប្រហែលជាមួយគីឡូពីរគីឡូដីដែរណាស់
ទៅដងមួយកំសៀវយើងនឹងកំសៀវប្រាំលីត្រណាស់កូនណាស់ដងយកមកទុកហូបដល់ទៅអញ្ចឹងឃើញអើចុះវានៅជិតមាត់ផ្លូវដែរផ្លូវជាតិណាស់កូនណាស់ឃើញប្រជាជននៅនឹងសហាករណ៍គេចេញមកក្រៅណាស់កូនគេជំលៀសចេញមកគេសប្បាយគេណាស់ចាសនៅជិតខែចូលឆ្នាំ
អ៊ុំលួចសួរគេទៅគេប្រាប់ណាស់ស្រាប់តែទៅវិញទៅប្រាប់គ្រួសារអញ្ចឹងទៅនិយាយតគ្នាប្រាប់អ្នកទាំងប៉ុន្មានដែរទៅដងទឹកនឹងណាស់កូនណាស់អ្នកធ្វើការនឹងណាស់ទៅៗធ្វើការផ្សេងដល់ម៉ោងប្រាំទៅ សុំគេមកគេមិនអោយមកគេអត់អោយមកគេថានៅៗតិចទៀតទៅប៉ុន្តែគេអោយជីចរណ្តៅហើយណាស់កូនណាស់គេយកយើងរែកប់នឹងរណ្តៅណាស់នឹងចេះតែនាំគ្នាចេញមក(មានសំលេងរំខានពីខាងក្រៅ)
ចេញមកសាមសិបគ្រួសារចេញមកចូលជាមួយគេដែលគេនឹងផ្លូវនឹងណាស់កូនណាស់សហាករណ៍ពួកប្រជាជនដូចថាមូលដ្ឋានគេអញ្ចឹងណាស់សុំគេចេញមក(មានសំលេងរំខានពីខាងក្រៅ)
បានចេញដូចថាវាបែកខ្ញែកគ្នាទៅអស់ទៅណាស់យើងចេះតែប្រជ្រៀតចូលជាមួយគេកុំអោយវារកយើងឃើញអញ្ចឹងទៅណាស់កូនពេលព្រលប់ៗទៅដេកនៅក្រោមស្ពានអញ្ចឹងទៅចេះតែទ្រាំសិនទៅណាស់កូនណាស់(មានសំលេងរំខានពីខាងក្រៅ)
ចូលទៅក្រោមស្ពានក្រោមអីនឹងចេះតែសម្ងំៗសិនទៅចេះតែដើរៗមកទៅបានព្រះតាមជួយថែរក្សារហូតមកនឹងមករហូតមកដល់សៀមរាប
ដើរមកដល់សៀមរាបៗបន្ទាប់មកក៏យកពួកវៀតណាម
អឺ....ពួកឡាននឹងគេទារក្នុងមួយម្នាក់មួយជីណាស់កូនណាស់គេទារយើងម្នាក់មួយជី

កូនរបស់អ៊ុំនឹងវាប៉ុន្មានអ្នកទេនេះប្រាំមួយនាក់
ហើយអ៊ុំម្នាក់ទៀតនឹងប្រាំបីនាក់ហើយណាស់ទាំងម្ដាយណាស់!

ក៖ កូនរបស់ម៉ាមានឈ្មោះអីខ្លះដែរទៅម៉ា?

ខ៖ កូនរបស់ម៉ាអាបងគេនឹងឈ្មោះ អ៊ិន ស៊ាវលី ចាសហៅវ៉ា!

ក៖ ចាសម៉ា!

ខ៖ ឈ្មោះក្រៅហៅវ៉ាណាស់កូនណាស់!

ក៖ ចាសម៉ា!

ខ៖ ចាសកូន! ហើយបន្ទាប់មកឈ្មោះល័ក្ខណា ចាសហើយបន្ទាប់មកទៀត អ៊ិនលាភ ហើយបន្ទាប់មកទៀតឈ្មោះ អ៊ិនកួច ហើយបន្ទាប់មកទៀតឈ្មោះអ៊ិននាដ ហើយបន្ទាប់មកទៀតឈ្មោះភាដ!

ក៖ ចាសម៉ា!

ខ៖ ចាសប៉ុណ្ណឹងពៅគេហើយចាស!

ក៖ ចាសម៉ា! កូនរបស់ម៉ាមានស្រីប៉ុន្មានប្រុសប៉ុន្មាននាក់ដែរម៉ា?

ខ៖ ប្រុសតែម្នាក់កូន!

ក៖ អូ.....

ខ៖ ប៉ុន្តែកាលពីជំនាន់ប៉ុលពតនោះបាត់ពីរនាក់បាត់ទៅកូន គេយកទៅដូចថាយកទៅដាក់កន្លែងកុមារណាស់កូនណាស់
ទីកុមារណាស់ប៉ុន្តែនៅពេលដែលជំលៀសទៅនឹងមិនដឹងថាគេជំលៀសទៅណាអីទៅណីទេ(មានសំលេងរំខានពីខាងក្រៅ)
បើគេអោយចេញទៅរៀងៗខ្លួនអញ្ចឹងទៅណាស់ហើយកូននឹងចេញទៅជួបនៅតាមផ្លូវខ្លះទេកូន
ចាសអ្នកខ្លះទៅគេអោយទៅធ្វើការនៅខេត្តកំពង់សោមអីនឹងទៅៗក៏ជួបគ្នាទៅណាស់យើងដើរទៅក្នុង....ចេញមកគេជំលៀសចេញមកនឹងណាស់ជួបគ្នានៅតាមផ្លូវនឹងក៏ចេះតែនេះមកៗរហូតនឹងមកណាស់!

កៈ ចាសម៉ា! ហើយចុះកាលនឹងម៉ាមានក្រុមគ្រួសារនឹងបានរៀបការនៅក្នុងឆ្នាំណាដែរម៉ា?

ខៈ អូ.....ខ្ញុំរៀបការនៅក្នុងឆ្នាំ៩០.....៦១ (ឆ្នាំ១៩៦១) កូនឆ្នាំ១៩៦១ ដឹងប៉ុន្មានឆ្នាំនឹងអុំមិនចាំទេដឹងតែ៦១ណាស់កូនណាស់!

កៈ ចាសម៉ា!

ខៈ ទូ អេងឡាយ គាត់មកស្រុកខ្មែរកាលនឹងជំនាន់នឹងណាស់នឹងហើយម៉ារៀបការ!

កៈ ចុះកាលជំនាន់នឹងម៉ារៀបការដោយសារតែស្រលាញ់ឬក៏ឪពុកម្តាយជាអ្នករៀបចំទុកដាក់អោយដែរម៉ា?

ខៈ ឪពុកម្តាយរៀបការអោយត្រឹមត្រូវទេកូន!

កៈ ចាសម៉ា!

ខៈ នេះរៀបការនៅនឹងផ្ទះរាល់ថ្ងៃនេះជំនាន់ពីសង្គមណាស់កូនណាស់!

កៈ ចាសម៉ា!

ខៈ ហើយទៅ.....

កៈ ហើយចុះលោកតាគាត់មានឈ្មោះអីដែរម៉ា?

ខៈ លោកតាឈ្មោះមានថា អ៊ិន ឈន់ ហៅថ ឆាង!

កៈ ហើយទៅគាត់នៅនឹងស្រុកជាមួយនឹងម៉ាដែរហ៏ម៉ា?

ខៈ ស្រុករកាកោងចំណែកម៉ានៅនឹងភ្នំពេញនឹងទេ ម៉ាកើតនៅនឹងម៉ងកើតនៅនឹងភ្នំពេញនឹងម៉ងណាស់កូនណាស់ហើយនៅពេលដែលម៉ាកើតមកធំដឹងក្តីនឹងមកស្រុកកំណើតពីម៉ែពីឪជីដូនជីតានៅខាងកំពតខ្លះ នៅខាងខេត្តតាកែវនឹងខ្លះខាងម្តាយនៅខាងខេត្តកំពតហើយចំណែកខាងឪពុកនៅខាងខេត្តតាកែវណាស់កូនណាស់!

កៈ ចាសម៉ា!

ខៈ នៅនឹងបន្ទាយព្រែក សប្បាយយើងនេះណាស់កូន!

កៈ ចាសម៉ា! ម៉ាសព្វថ្ងៃនឹងមានទីលំនៅៗភូមិឃុំណាដែរម៉ា?

ខ៖ ខ្ញុំនៅបឹងកក់ទី២ នៅនឹងសង្កាត់បឹងកក់ទី២ណាស់កូនណាស់!

ក៖ ចាសម៉ា! ហើយអឺ.....ស្រុកកំណើតក៏នៅនឹងភ្នំពេញនឹងដែរហ៎ម៉ា?

ខ៖ ចាសកូន! នៅនឹងម៉ងនៅនឹងវត្តនាគវ័ន្តនឹងម៉ងណាស់កូនណាស់ នៅខាងជើងកាលពីមុនម៉ានៅខាងជើងណាស់កូនណាស់ ដល់តែពេលដែលម៉ាមានគ្រួសារនឹងទៅក៏ម៉ែចែកដីមកក៏មកនៅនឹងម៉ងទៅណាស់កូនណាស់!

ក៖ ចាសម៉ា!

ខ៖ ម៉ែចែកដីស្រែមកនឹងក៏មកនៅនឹងៗម៉ងទៅ!

ក៖ អញ្ចឹងម៉ាបែកពីអាពតនឹងមកបានមករកស្រុកកំណើតនឹងវិញ?

ខ៖ ចាសកូន! គេអោយមកស្រុកកំណើតវិញណាស់កូន!

ក៖ ចុះកាលនៅជំនាន់ប៉ុលពតនឹងគេបានជំលៀសម៉ានឹងក្រុមគ្រួសារទៅណាដែរម៉ា?

ខ៖ ទៅអឺ....មុនដំបូងនឹងទៅអូរត្រជាក់ចិត្ត(មានសំលេងរំខានពីខាងក្រៅ) ជំលៀសចេញពីនឹងទៅៗតំណាក់ហើយណាស់កូនណាស់!

ក៖ ចាសម៉ា!

ខ៖ ដាក់តាមរទេះភ្លើងនឹងទៅៗតំណាក់នឹងទៅក៏គេអោយនឹងទៅទៀតទៅដល់...ទៅដល់ភូមិល្អងនឹងនៅក្នុងពោធិសាត់គេអោយយើងចុះនៅនឹងម៉ងកូននៅជាសហករណ៍នៅនឹងម៉ងណាស់កូន នៅបានប៉ុន្មានទេគេក៏ជំលៀសយើងនឹងទៅទៀត!

ក៖ អឹម!

ខ៖ ចាសបញ្ជូនទៅទៀតនឹងក៏គេបញ្ជូនទៅចាមរអា ទៅអូរត្រជាក់ចិត្តអីអញ្ចឹងទៅណាស់ ហើយទួលថ្នួចអញ្ចឹងទៅណាស់កូនណាស់ ទៅបីបួនកន្លែងឯណោះទៅច្រើនកន្លែងណាស់កូនដល់ពេលដែលត្រឡប់មកវិញជិតបែកនឹងបានម៉ាវិលត្រឡប់មកពីនឹងមកគេចាប់បាន(មានសំលេងរំខានពីខាងក្រៅ) គេអោយមកនៅនឹងភូមិល្អងវិញណាស់កូនណាស់ដល់តែពេលអ្នកណាមួយចូលមកថាមកជួយណាស់ អើ....អានឹងខ្ញុំមិនដឹងដែរណាស់កូនណាស់លឺតែថាគេមកជួយនឹងយើងត្រេកអរណាស់កូន

ណាស់ក៏នាំគ្នារត់ចេញមកទៀតៗមកតាមរហាត់ទឹក
មកតាមរហាត់ទឹកនឹងចេញមកតាមច្រាំងម្លូរមកខាងទន្លេសាប ដៃទន្លេសាបកូន
ចាសមកតាមដៃទន្លេសាបនឹងរហូតបានម៉ាវាអស់លុយអស់អីទៅនឹង(មានសំលេងរំខានពីខាងក្រៅ)
ដោយសារតែមាសនឹងចេះតែកេងទុកសំរាប់ធ្វើដំណើរដែលឆ្លងកាត់ពិបាកខ្លាំងណាស់កូន!

កៈ អឺម....ចាសម៉ា!

ខៈ ដល់អញ្ចឹងទៅមកដល់ដៃទន្លេសាបនឹងអត់មានស្អីទេណាស់កូន
មានតែទឹកហើយនឹងមេឃនឹងទេណាស់តែមានគ្នាប្រហែលជា២០ទៅ៣០គ្រួសារដែរតែគេមក
នៅមុនហើយអ្នកដែលគេមកក្រោយនៅក្រោយអញ្ចឹងទៅណាស់កូន!

កៈ ចាសម៉ា!

ខៈ ដល់នេះទៅម្នាក់នោះគេមានទូកពុកណាស់
វាបាក់អញ្ចឹងទៅគេខំរកក្តារយកមកវ៉ែចឹងទៅគេយកម្នាក់មួយជីដល់តែគេយកក្នុងមួយម្នាក់មួយជីដល់ហើយគេអោយមកដល់អញ្ចឹងអ៊ីប្រាំមួយអ្នកប្រាំបីនាក់នឹងអស់ប្រាំបីជីដែរណាស់(មានសំលេងរំខានពីខាងក្រៅ)
ដល់ហើយទៅតាយាយនោះគាត់នៅធ្វើការខាងរទេះភ្លើងនឹងដែរតែគាត់កាន់ខាងក្បាលម៉ាស៊ីណាស់គាត់ក៏សុំមកនៅជាគ្នានឹងមកនឹងហើយសុទ្ធតែអ្នកនៅនឹងទូលផ្តួចណាស់កូនណាស់មកជាមួយគ្នាមកដល់សៀមរាបអត់
អត់ដឹងថាអត់ស្គាល់ដំបូងមកដល់ខាងនឹងយើងមកដល់ដៃទន្លេសាបណាស់កូនណាស់
នឹងហើយដល់ហើយកូនអើយអត់ដឹងស្រាប់តែចុះទៅៗគ្រាន់តែភក់នឹងត្រឹមនេះ!

កៈ អឺម!

ខៈ
ក៏បានអៀវកូនអៀវអើយកមកដាក់គោកទៅណាស់ភក់វាជ្រៅៗពេកចុះដៃទន្លេសាបហើយម៉ានឹងក៏មិនដែលឆ្លងកាត់ដែរតាំងពីមុនមកនឹងទើបតែនៅជំនាន់អាពតនឹងទេ
ទៅអញ្ចឹងទៅក៏អត់មានស្អីទេគេចូលក្នុងសហករណ៍
អត់ចូលទេណាស់កូនណាស់សុំគេមកភរគេផងអីផងព្រោះយើងអត់ដឹងមិនដឹងថាទៅឯណាមកឯណីទេណាស់ ក៏សុំគេមក(មានសំលេងរំខានពីខាងក្រៅ)
ប្រាប់គេថាខ្ញុំសុំមកខេត្តសៀមរាបព្រោះមានបងប្អូននៅសៀមរាបប្រាប់គេអញ្ចឹងណាស់ក៏អត់

ចូលនឹងគេទេក៏មកដល់ដើរពីទន្លេសាបនឹងមកមកដល់ដេកនឹងវត្តភ្នំក្រោមណាស់កូន ដេកពីរបីថ្ងៃអញ្ចឹងទៅគេចែកអង្ករពោតសាលីម្នាក់មួយកំប៉ុងៗអញ្ចឹងទៅណាស់ ដល់ពេលនេះទៅសុំគេមកទៀតព្រោះយើងអត់ចេះនៅទេណាស់កូនណាស់ អត់ចេះនៅទេចេះតែនឹកទៅដល់ម៉ែឪមិនដឹងថាអ្នកណាស្លាប់អ្នកណារស់ទេបែកខ្ញែកគ្នាអស់អញ្ចឹងណាស់កូនណាស់!

ក៖ ចាសម៉ា!

ខ៖ ក៏សុំគេមកទៀត សុំគេមកអញ្ចឹងក៏មកដល់កន្លែងគេចិញ្ចឹមក្រពើ អាងចិញ្ចឹមក្រពើគេហៅថាកន្លែងដំដែកណាស់កូនណាស់ចាស ដេកនៅនឹងបានដូចជាពីរយប់បានសួរគេទៅគេថាអាផ្លូវនេះទៅអង្គរវត្តហើយអាផ្លូវនេះមកភ្នំពេញហើយអាផ្លូវនេះត្រូវទៅជំរុំអីអញ្ចឹងទៅណាស់កូនណាស់ទៅជំរុំទល់ដែលថៃណាស់!

ក៖ ចាសម៉ា!

ខ៖ នឹកថាម៉ែឪមិនដឹងថាទៅណាមកណាីនោះទេ គេខ្លះគេទៅជំរុំទៅហើយម៉ាអត់ចិត្តដាច់ណាស់កូនក៏សុំគេមកផ្លូវភ្នំពេញវិញមកយើងមករកផ្ទះសំប្បែងរកបងរកប្អូនណាស់កូនណាស់!

ក៖ អឺម!

ខ៖ ចាសនឹងហើយ ក៏មកដល់ៗអញ្ចឹងគេយកម្នាក់ជីឡានណាស់កូនណាស់បានតែម៉ាអស់ៗនឹងអស់ដោយសារតែសាហ៊ុយចាយវាយអញ្ចឹងនឹងឯងណាស់កូនណាស់ ហើយនៅពេលមកដល់គេដាក់យើងចោលនៅនឹង(មានសំលេងរំខានពីខាងក្រៅ) គីឡូលេខ៦នេះ ចាសឡាននឹងណាស់គេយកលុយហើយអីហើយក៏នាំគ្នាជាមួយនឹងប្ដីដាក់ឥវ៉ាន់នៅលើអាណួររីនឹងចេះតែនាំគ្នារុញមកទៅព្រោះយប់ដែរហើយស្រាប់តែវៀតណាមវានៅពេញភូមិវាអត់អោយយើងចូលទៅទេណាស់កូនណាស់ក៏នាំគ្នាមកដេកនៅនឹងកុដិលោកនឹងមួយយប់(មានសំលេងរំខានពីខាងក្រៅ) ស្អែកឡើងបានគ្រួសាររបស់អ៊ុំទៅកន្លែងធ្វើការទៅៗរកមេរកកើយទៅណាស់ ជួបលោកយុនឈីៗក៏លោកសួរនាំអីទៅគាត់សង្ឃរាជវត្ត(ព្រះចៅអធិការវត្ត) នឹងក៏បានលោកអោយគេយកឡានទៅដឹកប្រជាជនកម្មកររទេះភ្លើងពីបាត់ដំបងនឹងមកព្រោះ

ទៅប៉ែកខាងនឹងទាំងអស់ណាស់កូនណាស់ជំលៀសទៅនឹងណាស់នឹងហើយអ្នកពីភ្នំពេញទៅនឹងរកឡានរកអីទៅដឹកនឹងមកបានអាចដំណើរការរទេះភ្លើងនឹងបានដើរណើរការបានវិញណាស់កូនណាស់
ចឹងស្រាប់តែទៅដល់ពួកវៀតណាមនឹងវាងងឹតទៅចេញផ្ទះរបស់យើងវាមិនសូវល្អដែរណាស់កូនណាស់ក៏សុំគេនៅទៅក៏គេអោយអាកូនអ៊ុំអាបាត់ខ្លួននោះគេអោយបាញ់ដូងបាញ់អីទៅវាចេះតែបាញ់អោយគេទៅក៏គេអោយផ្ទះនឹងមកយើងនៅវិញទៅណាស់កូនណាស់
នឹងហើយដល់អញ្ចឹងបានម៉ាទៅលក់ត្រីលក់អីទៅហើយទៅគ្រួសារក៏ចូលធ្វើការនៅនឹងកន្លែងរទេះភ្លើងវិញនឹងទៅណាស់កូនណាស់ ដល់តែលក់អត់បានម៉ាធ្លាក់ខ្លួនឈឺ!

ក៖ អូ....

ខ៖ ឈឺក៏ទៅរកបងប្អូននៅនឹងស្ទឹងត្រែងឯណោះ ព្រោះពីសង្គមម៉ាធ្លាប់ទៅដែរណាស់កូនណាស់នៅចាំផ្លូវទៅនឹង
(មានសំលេងរំខានពីខាងក្រៅ)
ទៅដល់វេទនាណាស់អ៊ុំទូកទៅនឹងទៅក៏ម៉ានឹងអត់ស្រួលខ្លួនទេ (យំ ស្តាប់អត់បានច្បាស់) ហើយគេនោះគេយ៉ាប់ដៃរណាស់កូនណាស់គេនឹងគេធ្វើពេទ្យណាស់កូនណាស់!

ក៖ ចាសម៉ា

ខ៖ ពេទ្យខេត្តណាស់ ដល់អញ្ចឹងគ្រួសារខ្ញុំនឹងក៏ប្រាប់ថាអោយឯងមកវិញមករកស៊ីវិញទៅម៉ាក៏រៀងបានគ្រាន់បើហើយក៏ទិញត្រីងៀតទិញប្រហុកអីយកទៅលក់ទៅណាស់កូនណាស់!

ក៖ ចាសម៉ា!

ខ៖ ទៅលក់តាមកាណូនតាម កាលនឹងអាពតវានៅធ្វើបាបនៅឡើយនៅតាមផ្លូវនឹងកូនទៅទិញត្រីងៀតនៅផ្សារថ្មីគេនឹង ត្រីឆ្អើរនឹងខ្លះទៅត្រីឆ្អើរត្រីរៀលត្រីអីនឹងណាស់កូនណាស់ត្រីប្រលាក់ត្រីអីខ្លះទៅក៏បានខ្លះទៅផ្អកប្រហុកម៉ាំអីខ្លះទៅយកទៅធ្វើលាយលក់ទៅកូនណាស់(មានសំលេងរំខានពីខាងក្រៅ)
លក់ផ្សារស្ទឹងត្រែងនឹងទៅយកទៅលក់នឹងទៅ(មានសំលេងរំខានពីខាងក្រៅ)
បីបួនឆ្នាំទៅទាហានគេផ្លាស់អស់ទៅកូនណាស់យើងក៏លក់វាមិនសូវជាដាច់ទេណាស់ព្រោះឡូវវាស៊ីទេរបស់ប្រៃហើយទៅប្រហុករបស់គេអត់ដូចជាប្រហុករបស់យើងទេ
ប្រហុករបស់គេជាទឹកកភក់ៗទេណាស់កូនណាស់ចាសហើយប្រហុករបស់យើងចំជាសាច់ត្រីសុ

ទូៗណាស់នឹងហើយនៅរ៉ឹងសាច់
អញ្ចឹងទៅក៏វាអស់ដូចថាវាអស់ទាហានទៅខ្លះក៏គេប្តូរទៅគីឡូលេខពីរនឹងខ្លះ
ហើយខ្លះទៀតក៏ប្តូរទៅណាផ្សេងៗទៀត
នៅនឹងគេដូចថាទៅកាប់ព្រៃកាប់អីនឹងណាស់ដូចជាអ្នកទៅធ្វើដូចថាទៅធ្វើអាឈើអាអីអញ្ចឹងទៅយើងក៏ចេះតែលក់ដាច់ណាស់តែដល់ពេលគេនេះអញ្ចឹងទៅក៏ចេះទេលក់ទៅហើយម៉ាកាលនឹងម៉ានៅបានបួនឆ្នាំបានម៉ាត្រឡបមកវិញហើយនិយាយពីតាមផ្លូវត្រឡបមកវិញនឹងពិបាកណាស់កូនអើយ ឡើងពីនេះទៅជិះកាណូន(មានសំលេងរំខានពីខាងក្រៅ) ជូនកាលទៅជួបអាពត(ប៉ុល ពត) វាកាត់មុខយើងទៅណា !

កៈ អឺ...ចាសម៉ា!

ខៈ វាកាត់មុខយកឥវ៉ាន់យើងទៅណា តែវាកាត់យកបានតិចតួចទេ បើពួកឡាវវាអស់ច្រើនព្រោះវាទិញអង្ករយកទៅហ្អាស(មានសំលេងរំខានពីខាងក្រៅ) វាទិញអង្ករយកទៅស្រុកវា អង្ករគេត្រូវការណាស់ ហើយថ្នរពិលក៏ត្រូវការដែរ ពួកនៅក្នុងព្រៃនិងណាកូនណា!

កៈ ចាសម៉ា!

ខៈ ហើយអ៊ីវិញមានប្រហុកត្រីងៀត អីនិងគេសុំឲ្យគេទៅ(មានសំលេងរំខានពីខាងក្រៅ) ចេះតែឲ្យគេទៅណាកូនណាបន្តិច បន្តួចទៅ ហើយធ្វើមិចកុំឲ្យតែវាអស់ទាំងអស់ណា បើពួកឡាវយកអស់អង្ករមួយកាណូតៗ!

កៈ អឺ...!

ខៈ យកអស់តែម្តង!

កៈ និងពេលសម័យដែលចូលអាពត(ប៉ុល ពត)មុនដំបូងឬក៏ទើបដាច់សម័យនិងទៅម៉ា?

ខៈ អានិងពេលយើងបែកមកហើយប៉ុន្តែយើងនៅទៅរកទទួលទាន បន្តិច បន្តួចតាមព្រៃណាកូនណា!»

កៈ ចាសម៉ា!

ខៈ វាកាត់ហៅអញ្ចឹងជូនណាវាលីអាបេ(គ្រាប់សម័យសង្គ្រាម)អញ្ចឹងទៅ!

កៈ ចាស!

ខ៖ កាណូតចូលទៅហើយយើងជិះកាណូតឡើងមក ទៅទឹកកំពុងតែហូរខ្លាំងកូនណា កោះរងាវ កោះអីនិង ទឹកហូរខ្លាំងណាស់កូន!

ក៖ អឺ...!

ខ៖ ចាស ឡើង ៗពីត្រឹមក្រចេះទៅណាកូនណា!

ក៖ ចាស!

ខ៖ កាលហ្នឹងអ្នកខ្លះគេជិះឡានទៅ ប៉ុន្តែអ៊ុំឥវ៉ាន់ច្រើនកំប៉ិកកំប៉ុកក៏អ៊ុំសុខចិត្តជិះកាណូតទៅណា(មានសំលេងរំខានពីខាងក្រៅ)!

ក៖ ចាសម៉ា!

ខ៖ គេអ្នក អត់ឥវ៉ាន់ច្រើនអត់អីទៅ គេឡើងឡានទៅ!

ក៖ ចាសម៉ា!

ខ៖ អានិងវាអញ្ចឹងណា(មានសំលេងរំខានពីខាងក្រៅ) ដល់អ៊ុំ បួនឆ្នាំទៅចេះតែលក់ដូរទៅជូនណា អ្នកស្រុកអ្នក ភូមិយកល្ហុងមកលក់ទៅចេះតែលក់ដូរទៅ(មានសំលេងរំខានពីខាងក្រៅ)ទិញចេកទិញអីទៅ ដល់ពេលពួកគីឡូពីរគេរចុះមកទៅពួកទាហ៊ាននិងគេចុះមកគេត្រូវការទិញគេទិញទៅណា ព្រោះយើង លក់ទាល់ល្ងាចទៅណាកូនណា!

ក៖ ចាសម៉ា(មានសំលេងរំខានពីខាងក្រៅ)!

ខ៖ ដល់ល្ងាចទើបអ៊ុំបររទេះនិងត្រលប់មកវិញទៅ(មានសំលេងរំខានពីខាងក្រៅ) សំរាកលាងទុកដាក់របស់របរស្អីៗទុកដាក់អីៗទៅណាកូនណា យកត្រីអីទៅលាងនៅទន្លេរទៅ យកទៅប្រលាក់ឲ្យវាប្រៃទៅហើយ ឲ្យវាស្អាតទៅ!

ក៖ ចាសម៉ា!

ខ៖ ហើយទៅស្អែកឡើងយើងយកទៅរៀបដាក់លក់វិញអញ្ចឹងទៅ!

ក៖ អឺ....!

ខ៖ មានផ្អក មានលាយមុំ អីចេះតែធ្វើលក់ទៅកូន(មានសំលេងរំខានពីខាងក្រៅ) អញ្ចេកជីវិតយើងចេះតែតស៊ូទៅណា!

កៈ ចាសម៉ា!

ខៈ ហើយអ៊ុំបាន ទាហ៊ាន ដោយថាខ្មែរយើងចូលចិត្តញាំផ្អែមណាកូនណា!

កៈ ចាសម៉ា!

ខៈ តែពួកនិងចូលចិត្តប្រៃ ហើយនិងជូរ(មានសំលេងរំខានពីខាងក្រៅ) ហើយហិរអញ្ចឹងដល់យើងអត់ទេដល់ឈប់រកបានគេមិនហូបទេ ហើយបន្ទាប់មកយាយលក់មិនសូវបានយាយក៏ឈប់លក់ទៅ(មានសំលេងរំខានពីខាងក្រៅ) មានអ៊ុំទិញត្រីនៅផ្សារ៧មករានិង(ស្តាប់មិនបាន)រហូតដល់គ្រួសារគាត់ធ្លាក់ខ្លួនឈឺគាត់ឈឺកូនណា!

ខៈ ចាសម៉ា!

កៈ ឈឺរហូតដល់គាត់ស្លាប់(មានសំលេងរំខាននៅខាងក្រៅ) បានអ៊ុំទៅស្រុកខាងគាត់នៅរកាកោងទៅទៅធ្វើស្មៅអីដីសល់តិចតួច ហើយដាំដំណាំអីតិចតួចទៅណាកូនណា(មានសំលេងរំខានពីខាងក្រៅ) ហើយចេះតែតស៊ូជាមួយកូនហើយចេះតែត្រដេត្រដរទៅណាកូនណា ខំតស៊ុទៅទំរាំដល់ថ្ងៃនេះ (មានសំលេងរំខានពីខាងក្រៅ) រហូតដល់សព្វថ្ងៃនេះទៅអ៊ុំទៅរកាកោងអត់បានព្រោះរឿងម៉ាមិនទៅចំការនិងកូនវាមិនឲ្យទៅបានជាអញ្ចឹងវា(ស្តាប់មិនបាន) ព្រោះអ៊ុំអ្នកដំណើរទេណាកូនណាព្រោះអ៊ុំអ្នកស្រុកខាងប្តីទេ!

កៈ ចាសម៉ា!

ខៈ អ៊ុំទៅធ្វើដីដែលគេឲ្យបន្តិចបន្តួចទៅ តិចៗទៅកូនណា ដល់ថ្ងៃមួយវាស្ងាត់និងពួកអាក្មេងៗវាញៀនគ្រឿងញៀននិងវាអាករយាយមួយមកពីវត្ត!

កៈ អូ...ចាស!

ខៈ មកពីបុណ្យក៏មិនដឹងមកពីវត្តមិនដឹង ព្រោះអ៊ុំក៏មិនបានចាំដែរណា គាត់មិនបានដោះមាសទុកគាត់ក៏ប្រញ៉ាប់ទៅកាប់ចេក វាឃើញស្ងាត់វាក៏ទៅអាករគាត់ស្លាប់យកមាសទៅ!

កៈ អ៎....ចាស!

ខៈ ពេលស្លាប់ទៅក៏កូនអ៊ុំវាភ័យវាលែងឲ្យអ៊ុំទៅៗ!

កៈ នៅស្រុកដែរម៉ា?

ខៈ នៅរកាកោងយើងនិងកូន ចាសរកាកោងនិង!

កៈ លឺអញ្ចឹងតែម្តងមែនទេម៉ា?

ខៈ អ៊ុំលឺគេនិយាយអញ្ចឹង តែអ៊ុំមិនបានទៅឃើញនិងភ្នែកទេណា អ្នកឈប់ទៅៗអ្នកឯង(បងប្អូនខាងប្តីហ្អាស)អ្នកឯងនៅតែឯងអញ្ចឹងយាយនោះមកពីបុណ្យ មានខ្សែរកមានក្រវិលអីនិងវាអាករយកអស់ហើយៗវាសម្លាប់ចោលទៀត(មានសំលេងរំខានពីខាងក្រៅ) !

កៈ អឺ….!

ខៈ ដល់កូនអ៊ុំដឹងអញ្ចឹងវាទៅពីនេះទៅក៏យកអ៊ុំមកវិញអត់ឲ្យអ៊ុំនៅខ្លាចណាស់ខ្លាចគេធ្វើបាបហ្អាស!

កៈ អញ្ចឹងផ្ទះនៅស្រុកនិងទុកចោលមែនទេម៉ា(មានសំលេងរំខានពីខាងក្រៅ)?

ខៈ ខ្ញមនិងកូនខ្ញមនៅចំការនិងបិទចោលទៅ!

កៈ ចំការអីនិងមានជួលគេទេម៉ា?

ខៈ អត់ទេ ដីនិងដូចជាដីគេរ៉ឹអាករពីខាងប្តីមកអញ្ចឹងទៅណា ចេះតែធ្វើៗទៅបើអត់ពីគាត់ហើយចេះតែធ្វើៗទៅណា(មានសំលេងរំខានពីខាងក្រៅ)ចេះតែធ្វើទៅដាំបាន ល្ហុងបានអីទៅបាន ស្ពៃអីទៅអ៊ុំចេះតែធ្វើទៅ ចេះតែបានបេះទៅកូនមួយថ្ងៃលក់បានបួយ៥ពាន់ មួយម៉ឺនអីទៅណា!

កៈ ចាសម៉ា!

ខៈ គ្រាន់ឲ្យកូនយកមកលក់នៅភ្នំពេញទៅ កូនវាមកទិញត្រីអីទៅ(ស្តាប់មិនបាន)ដល់ពេលផ្អើលអញ្ចឹងទៅកូនឈប់ឲ្យលក់ទៀតទៅណា កូនណា(មានសំលេងរំខានពីខាងក្រៅ )វាស្ទាត់ដៃរកូនចុះទៅកូនដោយសារវាឆ្ងាយដៃរកូនចុះទៅប្រហែលមួយរយម៉ែត្រទៅពីររយម៉ែត្រជាងដៃរចុះទៅកូន(មានសំលេងរំខានពីខាងក្រៅ)ធម្មតាក៏ខ្លាចដៃរកូនណាវាស្ទាត់!

កៈ ចាសម៉ា!

ខ៖ (មានសំលេងរំខានពីខាងក្រៅ) ដល់អញ្ចឹងទៅក៏កូនវាលែងឲ្យទៅទៀតទៅបានអ៊ុំអត់អីធ្វើចេះតែមកនៅវត្តបំរើលោក(ព្រះសង្ឃ)ទៅណា(មានសំលេងរំខានពីខាងក្រៅ)!

ក៖ ចុះម៉ា(មានសំលេងរំខានពីខាងក្រៅ)ចុះកាលម៉ាមកនៅនិងម៉ាមកមានរយះពេលប៉ុន្មានទៅ?

ខ៖ អ៊ុំមកនិងអ៊ុំលក់ត្រីអញ្ចឹងទៅ(មានសំលេងរំខានពីខាងក្រៅ) ចេះតែរស់ហើយណាដល់ពេលគ្រួសារស្លាប់(ស្វាមីរបស់គាត់) បន្ទាប់មកអ៊ុំក៏ឈប់លក់ទៅ បើវាលក់អីក៏លក់ទៅអ៊ុំវាលេងគិតអីហើយណាកូនណា ធ្វើមិចឲ្យបានរស់សិនទៅ!

ក៖ ហើយម៉ាមកនៅវត្តនេះប៉ុន្មានឆ្នាំហើយម៉ា?

ខ៖ មកនៅជាងមួយឆ្នាំហើយកូន(មានសំលេងរំខានពីខាងក្រៅ) គ្រាន់តែអ៊ុំមកទៅបោសច្រាសបន្តិចទៅ ត្រូវធ្វើអីធ្វើទៅ ដាំបាយដាំទឹកប្រគេនលោក(ព្រះសង្ឃ)ទៅណាកូនណារហូតដល់ពេលលោក(ព្រះសង្ឃ)ឆាន់ហើយអញ្ចឹងទៅអ៊ុំរៀបចំទុកដាក់ចានឆ្នាំងហើយទៅ បានអ៊ុំត្រលប់ទៅផ្ទះវិញទៅ ដល់ពេលព្រឹកឡើងអ៊ុំមកទៀតអញ្ចឹងទៅ!
ជួនណាមានគេមន្ត(និមន្ត)លោក(ព្រះសង្ឃ)ទៅសូត្រមន្តអញ្ចឹងទៅលោកប្រាប់(ព្រះសង្ឃ) ហើយទៅអ៊ុំក៏ទៅសូត្រមន្តជាមួយលោក(ព្រះសង្ឃ)ដែរទៅណាកូន(មានសំលេងរំខានពីខាងក្រៅ)!

ក៖ ចាសម៉ា!

ខ៖ គ្រាន់បានគេជូនបច្ច័យអីបន្តិចបន្តួចគ្រាន់បានហូបទៅកូន(មានសំលេងរំខានពីខាងក្រៅ)អញ្ចឹងរាល់ថ្ងៃទៅ!

ក៖ ចុះកូនចៅម៉ាអីគាត់មកជុំគ្នានៅផ្ទះឬនៅឯណាទៅ(មានសំលេងរំខានពីខាងក្រៅ)?

ខ៖ នៅផ្ទះតែមួយ(មានសំលេងរំខានពីខាងក្រៅ)ទេកូនប៉ុន្តែអាអ្នកបែកក៏បែកខ្លះទៅនាកូនណាអាអ្នកស្លាប់ៗទៅដល់រាល់ថ្ងៃនៅតែ៥នាក់ទេកូន(មានសំលេងរំខានពីខាងក្រៅ!

ក៖ ចុះលោកតាគាត់ស្លាប់យូឆ្នាំហើយនៅម៉ា?

ខ៖ គាត់ស្លាប់យូរហើយកូន គាត់ស្លាប់ជាង១០ឆ្នាំហើយ(មានសំលេងរំខានពីខាងក្រៅ)!

ក៖ ចាសហើយ កូនចៅរបស់ម៉ាគាត់ធ្វើការអ្វីខ្លះដែរ(មានសំលេងរំខានពីខាងក្រៅ)?

ខ៖ នៃកូនស្រីធ្វើការនៅធនាគារដែរ(មានសំលេងរំខានពីខាងក្រៅ) ក្រៅពីនិងសុទ្ធតែអ្នករកស៊ីទេកូន ហើយអាបងគេបង្អស់និងធ្វើខាងប៉ូលីសមានតែប៉ុណ្ណឹងទេ!

ក៖ ចាស គាត់នៅតាមខេត្តឬនៅភ្នំពេញនិងទេ?

ខ៖ នៅភ្នំពេញទេនិងកូន(មានសំលេងរំខានពីខាងក្រៅ)!

ក៖ នៅភ្នំពេញទាំងអស់គ្នាទេន៎ម៉ា?

ខ៖ ចាសនៅភ្នំពេញទាំងអស់គ្នា!

ក៖ ពេលថ្ងៃបុណ្យទានអីគាត់មកលេងទេម៉ា?

ខ៖ មកជុំគ្នាដែរកូន(មានសំលេងរំខានពីខាងក្រៅ)!

ក៖ ចុះម៉ាមានបងប្អូននៅក្រៅប្រទេសដែរទេ?

ខ៖ មានៗដែរកូនទើបតែទៅទេណា(មានសំលេងរំខានពីខាងក្រៅ)នៅអាមេរិក!

ក៖ នៅរដ្ឋណាដែរម៉ា(មានសំលេងរំខានពីខាងក្រៅ)?

ខ៖ ម៉ាមិនស្គាល់ផងម៉ាអតើចាំ(មានសំលេងរំខានពីខាងក្រៅ)!

ក៖ ចុះគាត់មានទាក់ទងអីមកម៉ាដែរទេ?

ខ៖ មានៗទាក់ទងមកដែរ!

ក៖ ចាសម៉ា!

ខ៖ ចាសកូន!

ក៖ គាត់មានធ្លាប់មកលេងនៅខ្មែរដែរទេម៉ា(មានសំលេងលេងរំខាននៅខាងក្រៅ)!

ខ៖ អត់ទេទើបតែទៅ គ្នាទើបតែទៅទេគ្នាទើបតែទៅ(មានសំលេងរំខានពីខាងក្រៅ)គ្នាមានប្តីហើយមានកូនទៅអាមេរិកទៅ

វានៅតែឯងវាមេម៉ាយដែរក៏វាទៅៗតែមិនដឹងនៅរដ្ឋណាអ៊ុំក៏មិនបានសួរអ៊ុំភ្លេចទៅណាកូនណា (មានសសំលេងរខានពីខាងក្រៅ)!

កៈ ចាសម៉ា!

ខៈ អ៊ុំអត់បានសួរគេទេ(មានសំលេងរំខានពីខាងក្រៅ)!

កៈ ចាស!

ខៈ ដឹងតែថាទៅនៅអាមេរិក!

កៈ គាត់មានប្រាប់ម៉ាថាគាត់ទៅធ្វើការអ្វីដែរនៅនិង?

ខៈ អត់ទេវាទៅនៅជាមួយកូន ព្រោះកូនវាមានប្ដីខ្មែរយើងដែរតែគេកាលពីនិងគេជំលាស់ទៅពីជំរុំទៅ ក៏បានទៅចូលនៅនិងទៅ!

កៈ ចាសម៉ា!

ខៈ ពួកអាមេរិកមកយកយន្តហោះយកទៅណាកូន កាលជំនាន់អាពត (ជំនាន់ប៉ុល ពត) កាលនិងគេចូលទៅជំរុំ ថៃដាងអីនិងហ្នាកូន (មានសំលេងរំខានពីខាងក្រៅ)កាលជំនាន់នោះគេចូលទឹកដីថៃណាកូន!

កៈ ចាសម៉ា កាលនិងគេមកយកនៅថៃ?

ខៈគេមក យកនៅទឹកដីថៃ!

កៈ ចាសម៉ា!

ខៈ ដល់ហើយទៅបានគេមកលេងស្រុកហើយគេឃើញទៅគេមករៀបការអីទៅ ណាកូនណា!

កៈ អឺ….!

ខៈ ដល់ម្ដាយនៅតែឯងពេកកូនប្រុស ក៏គេមានគ្រួសារកូនពីរទាំងអស់ស្រីមួយប្រុសមួយ!

កៈ អឺ…!

ខៈ ដល់វាមានគ្រួសារទៅវាក៏ចង់ទៅតាមកូនពៅហ្នាស!

កៈ អឺ…!

ខ៖ ហើយកូនធានាបានយកទៅហើយ ទាល់តែគ្រប់ពីរឆ្នាំជាងបានគេឲ្យយើងមកខ្មែរបានណាកូនណា មកលេងស្រុកខ្មែរវិញណា!

ក៖ ចាសម៉ា!

ខ៖ យើងទៅនៅនិងទាល់ចូលសញ្ជាតិគេបានយើងមកបានណាកូនណា (មានសំលេងរំខានពីខាងក្រៅ)អញ្ចឹងបានអ៊ុំចាំមិនបានថានៅរដ្ឋណាទេ មិនដឹងរដ្ឋណាអត់ចាំ!

ក៖ ម៉ាកាលជំនាន់និង បងប្អូនម៉ានិងគាត់បានទៅ(មានសំលេងរំខានពីខាងក្រៅ) ម៉ាមានដឹងពត៌មានអីដែរទេ
និយាយថាគេយកយកយន្តហោះអីដឹងទៅ(មានសំលេងរំខានពីខាងក្រៅ)!

ខ៖ ដឹងតើកូន(មានសំលេងរំខានពីខាងក្រៅ)តែចិត្តអត់ចង់ទៅ ព្រោះម៉ែឪនៅនេះទាំងអស់កូន បងប្អូន៨ទៅ៩នាក់ឯណោះកូនមិនដឹងនរណារស់នរណាស្លាប់
រួចហើយចង់មមកស្រុកជាងកូនណា ផ្លូវវាមានបីដូចអ៊ុំថា មានផ្លូវដល់អង្គរវត្ត ហើយមានផ្លូវមួយយើងទៅខាងថៃ!

ក៖ ចាសម៉ា!

ខ៖ ដល់ផ្លូវមួយទៀតយើងមកស្រុកខ្មែរយើង(មានសំលេងរំខានពីខាងក្រៅ) មកភ្នំពេញវិញណាកូនណា!

ក៖ អញ្ចឹងម៉ាជ្រើសរើសផ្លូវមកស្រុកវិញ?

ខ៖ ម៉ារកផ្លូវមកស្រុកវិញ!

ក៖ មកជុំគ្រួសារន៎ម៉ា(មានសំលេងរំខានពីខាងក្រៅ) ពេលមកដល់បាបជួបជុំគ្រួសារដែរទេម៉ា?

ខ៖ ពេលមកបានជួបជុំ ប៊ិន(មានសំលេងរំខានពីខាងក្រៅ )មានអ្នកខ្លះក៏ស្លាប់ទៅណា អ្នកខ្លះក៏នៅមានជីវិតទៅណាកូនណា
អ្នកខ្លះក៏ស្លាប់ពីសង្គមទៅណាបងប្អូនហា(មានសំលេងរំខានពីខាងក្រៅ)!

ក៖ ចាសម៉ា!

ខ៖ ស្លាប់ជំនាន់អាពត( ជំនាន់ ប៉ុល ពត)តែប៉ុន្មាននាក់ទេកូន(មានសំលេងរំខានពីខាងក្រៅ)

ដូចជាបីនាក់ទេ បួននាក់ទេ!

កៈ អឺ....!

ខៈ ប្អូននាក់ស្លាប់ពីអាពត (ជំនាន់ប៉ុល ពត) ស្លាប់ពីសង្គមបីនាក់ណាកូនណា(មានសំលេងរំខានពីខាងក្រៅ)!

កៈ ចុះពូកគាត់បានស្លាប់ទៅនិងម៉ាមានទាន់និងភ្នែកដែរទេ(មានសំលេងរំខានពីខាងក្រៅ)?

ខៈ គាត់ស្លាប់ជំនាន់អាពតហ្អេស(ជំនាន់ ប៉ុល ពត)?

កៈ ចាសម៉ា!

ខៈ អត់ទាន់ទេព្រោះនៅកន្លែងខុសគ្នាកូន(មានសំលេងរំខានពីខាងក្រៅ)!

កៈ គ្រាន់តែលឺគេផ្ដល់ដំណឹងទេ(មានសំលេងរំខានពីខាងក្រៅ)!

ខៈ ចាស គ្រាន់តែគេឲ្យដំណឹងប្រាប់(មានសំលេងរំខានពីខាងក្រៅ)គេផ្ដល់ដំណឹងថាស្លាប់ហើយ ហើយចេះតែនាំគ្នាធ្វើទៅមានអីធ្វើនិងទៅណា!

កៈ ចាសម៉ា(មានសំលេងរំខានពីខាងក្រៅ)!

ខៈ ធ្វើមិចឲ្យតែរស់សិនទៅកូន(មានសំលេងរំខានពីខាងក្រៅ)!(ស្ដាប់មិនបាន) មកវិញកន្លែងទំនេរទាំងអស់!

កៈ កាលនិងដែរម៉ាគេប្រើឲ្យធ្វើអីខ្លះទៅ(មានសំលេងរំខានពីខាងក្រៅ)?

ខៈ គេឲ្យយើងទៅកាប់ដីគរឲ្យយើងទៅស្ទូង(មានសំលេងរំខានពីខាងក្រៅ)ទៅស្ទូងនៅខេត្តពោធិសាត់ហ៎ នៅខាងបាត់ដំបងកូន(មានសំលេងរំខាន ពីខាងក្រៅ)!

កៈ អឺ...!

ខៈ ទៅខាងឈ្មោះអីភូមិតាមូន (មានសំលេងរំខានពីក្រៅ)តាមនិងគាត់ខាងក្ដោបក្ដាប់នៅនិងឈ្មោះតាមូន!

កៈ ចាសម៉ា!

ខៈ ចាសនៅខាងពោធិសាត់ បាត់បងនិងហើយកូន មួយនិងហើយណាកូនណា!

កៈ ចាសម៉ា ! ម៉ាចាំបានល្អណាស់បានទាំងឈ្មោះទៀត!

ខ៖ ចាស ឈ្មោះភូមិនិងទៀត ទៅគាត់មានចិត្តធម៌ដែរណា តាប្រធានភូមិគាត់មានចិត្តល្អដែរណា(មានសំលេងរំខានពីខាងក្រៅ)ឧទាហរណ៍ថា អាពត(ប៉ុល ពត) វាមិនអមបិលទេតែវាលួចឲ្យយើងស៊ីណាកូនណា!

ក៖ ចាសម៉ា(មានសំលេងរំខានពីខាងក្រៅ)!

ខ៖ កាលនិងបានអំបិល ពីរបីគ្រាប់មកអរណាស់កូនជំនាន់និង(មានសំលេងរំខានពីខាងក្រៅ)បេះតែស្លឹក(ស្តាប់មិនបាន)បង់អំបិលតិចៗទៅនាំកូនហុតទៅណាមានអង្ករមានអីឯណា(មានសំលេងរំខាន)!

ក៖ ចាសម៉ា!

ខ៖ ជួនកាលរើសខ្ទៅបានពីរបីគ្រាប់ទៅដាក់ស្ងោរហូបទៅធ្វើមិចឲ្យតែរស់ទៅ ដាក់ឲ្យណែនៗពោះចេះតែដើរទៀតណាកូនណា!

ក៖ មិនស្រួលគេដឹងមានបញ្ហាទៀត!

ខ៖ អត់ទេកូនមានតែជួបអ្នកធម៌គេចេះតែឲ្យទានយើងទៅណា ជួនណាយើងដើរទៅជិះសេះទៅគេប្រាប់ជួនណា(មានសំលេងរំខានពីខាងក្រៅ)គេប្រាប់ថា ទៅផ្លូវនេះទៅឲ្យត្រង់ទៅបែកទៅ ៗអញ្ចេសទៅចុះទៅដៃទន្លេរសាប ដូចអ៊ុំនិយាយអញ្ចឹងទៅណា!

ក៖ អឺ….!

ខ៖ ដល់ដៃទន្លេរសាបនិងទៅដូចថាល្អដែរ(មានសំលេងរំខានពីខាងក្រៅ)គេមុនដំបូងទៅៗក្រោម ដើមឈើគេក្រាលក្រណាតើ គេចាក់ដូចថាមាននំនោងមានល្ពៅ មានអីទៅគេដាក់ទៅវាធ្ងន់ណាកូន ហើយមានអង្ករទៅដូចដូរគ្នាស៊ីអញ្ចឹងកូន(មនាសំលេងរំខានពីខាងក្រៅ)ដូចដូរគ្នាស៊ីអញ្ចឹង!

ក៖ ចាសម៉ា!

ខ៖ ចាសចេះតែដើរកាតើទៅយូរបានទៅដល់ចំការគេ(មានសំលេងរំខានពីខាងក្រៅ)គេដាំសុទ្ធតែ កាឆាយ!

ក៖ អឺ.....!

ខ៖
ដល់ចូលទៅមើលទៅឃើញមានប្រហុកបន្តិច(មានសំលេងរំខានពីខាងក្រៅ)សុំគេយកមកអញ្ចឹងទៅហើយយកអីមួយទៅដាក់ឲ្យគេវិញទៅ យកកាឆាយយកអីទៅហូបទៅណា ដែរអ៊ុំចង់និយាយដែរអ៊ុំដើរៗ(មានសំលេងរំខានពីខាងក្រៅ)ឆ្លងទៅ
ហើយកីតម្បាញអីនិងកូនណា ផុតពីកីតម្បាញនិងនិងទៅបានឆ្លងមកសៀមរាបវិញ(មានសំលេងរំខានពីខាងក្រៅ)ដល់គេចែកអង្ករពូជសាលីរួចបនាមានលុយជិះឡាន
មិនដឹងនិយាយថាមិចទេកូនអតើបានឃើញជាក់ស្តែង!

ក៖
កាលនិងម៉ាមានដែលឃើញគេយកមនុស្សទៅសម្លាប់ចោលដែរទេ(មានសំលេងរំខានពីខាងក្រៅ)?

ខ៖ អត់ទេ
អត់ឃើញទេប៉ុន(មានសំលេងរំខានពីខាងក្រៅ)គេនិយាយយើងចងនិងខ្សែរៗតែអ៊ុំមិនដឹងទេណា លឺតែគេនិយាយទេណាបើឲ្យឃើញជាក់ស្តែងនិងភ្នែកគឺអត់ទេ!

ក៖ អញ្ចឹងហ៎?

ខ៖ ចាស(មានសំលេងរំខានពីខាងក្រៅ)!

ក៖ ចាសម៉ា(មានសំលេងរខានពីខាងក្រៅ)!

ខ៖ និងម៉ាលឺគេនិយាយទេណាកូនណា!

ក៖ ចាសម៉ា(មានសំលេងរំខានពីខាងក្រៅ) ហើយចុះកាលនិងគេមានវាយធ្វើបាបម៉ាដែរទេ?

ខ៖ ហើយកូនហ្អើយបើយើងសមកម្មទៅគេមិនធ្វើបាបយើងទេ តែបើយើងខ្ជិលទៅគេកសាងយើង
គេហៅយើងទៅក៏សាងហ្អាកូនជំនាន់និងហ្អា(មានសំលេងរំខាននៅខាងក្រៅ)គេហៅទៅស្តីឲ្យតែគេហៅកសាងអញ្ចឹងណាកូនណា(មានសំលេងរំខានពីខដាងក្រៅ)!

ក៖ ចាសម៉ា(មានសំលេងរំខានពីខាងក្រៅ)!

ខ៖ អឺ...!

កៈ តែ..!

ខៈ
ប៉ុន្តែរអ៊ុំមិដែលឃើញគេយកទៅសម្លាប់ផ្ទាល់ភ្នែកទេណាកូនណា(មានសណលេងរំខានពីខាងក្រៅ)លឺតែនិយាយលឺមែន គេអ្នកនេះគេថាឲ្យឃើញ បើថាឲ្យឃើញផ្ទាល់ភ្នែកអត់ទេកូន(មានសំលេងរំខាន) វាជាការពិតមិនកុហកទេចាស!

កៈ ចាសម៉ា(មានសំលេងរំខាននៅខាងក្រៅ) ចុះពេលនិងគេបានឲ្យបបរម៉ាពិសារអញ្ចឹងហើយ!

ខៈ បបរ(មានសំលេងរំខានពីខាងក្រៅ)ក្រោយពីម៉ាត្រលប់ចូលភ្នំពេញវិញ ជួនណាទៅនំប៉័ងៗបានពីរ និយាយទៅមួយកំណាត់ម្នាក់ណាកូនណា មួយគេកាត់ជាពីរហ្អាស ចាសហើយនំប៉័ងគេធំដែរណាកូនណា(មានសំលេងរំខានពីខាងក្រៅ)បើកាត់ជាពីរបានម្នាក់មួយកំណាត់ ទាល់តែនេះទៅ បានបាយទៅ ជួនណាទៅវាមិនទៀងណាកូនណា ជួនណាបានបាយទៅសម្លរប្រហើរ
សម្លរអីអញ្ចឹងទៅមានចុងភៅគេល្អទៅហើយយើងចេញពីធ្វើការទៅ(មានសំលេងរំខាននៅខាងក្រៅ)ហើយធ្វើការរួចហើយយើងហូប!

កៈ ចាសម៉ា!

ខៈ ចាស!

កៈ ចាសម៉ា!

ខៈ និងម៉ាធ្លាប់ដឹងអញ្ចឹងកូន!

កៈ ពេលម៉ាបានអាហារគ្រប់គ្រាន់ទៅម៉ាធ្លាប់ឈឺដែរទេ(មានសំលេងរំខានពីខាងក្រៅ)!

ខៈ (មានសមលេងរំខានពីខាងក្រៅ) ខ្វះណាស់កូន ជួនណាហូបឆ្អែតទៅណាអត់ទៅ ជួនណាយកដើមចេកយើងយកអាឬសវា
ក្នុងមើមវាដូចធំណា(មានសំលេងរំខានពីខាងក្រៅ)យកមកចត្តឲ្យស្អាតទៅ
ដូចដំឡូងដែរកូនផុសៗណាកូនណា!

កៈ ចាសម៉ា!

ខ៖ អត់មានអំបិលបង់ផងអីផងសាបតែចេះតែហូបទៅ(មានសំលេងរំខានពីខាងក្រៅ)ជំនាន់អាពត និង(ជំនាន់ ប៉ុល ពត)!

ក៖ ចុះម៉ាតែគេឲ្យយើងកាប់អិកើតដែរន៎?

ខ៖ ចេះតែលួចទៅ គេទាន់ទៅគេចាប់ណាកូន គេទាន់ទៅគេកសាង(មានសំលេងរំខានពីខាងក្រៅ) ប៉ុន្តែអ្នកខ្លះគេជីកបានទៅ គេឲ្យខ្លះទៅ(ស្តាប់មិនបាន)ដូចថាធ្វើល្អ យើងធ្វើល្អណាកូនណា ពេលគេស្មោរអញ្ជឹងគេឲ្យយើងពាក់កណ្តាលមកយើងទៅ(មានសំលេងរំខានពីខាងក្រៅ) ហើយយើងអគុណគេទៅណាកូនណា យើងធ្វើអីអត់បានព្រោះគេនៅចង្ក្រានបាយណាកូនណា គេចេះតែមាននេះមាននោះគេចេះតែលួចឲ្យយើងទៅហើយយើងវិញក៏ហូបលាក់ការដែរណា(មានសំលេងរំខានពីខាងក្រៅ) និងវាមានអញ្ជឹងមែនតែបើឲ្យទៅធ្វើខ្លួនឯងធ្វើអត់កើតទេ!

ក៖ (មានសំលេងរំខានពីខាងក្រៅ) អញ្ជឹងហើយមានធ្លាប់ឈឺដែរទេ?

ខ៖ ធ្លាប់ឈឺដែរកូនតែឈឺទៅតែចេះតែប្រឹងទៅកូន(មានសំលេងរំខានពីខាងក្រៅ) ព្រោះថាខ្លាចងាប់ណាកូនណា អត់ហ៊ានតថ្លៃគេទេគេឲ្យធ្វើអីយើងត្រូវតែធ្វើនិងទៅណាកូនណា គេឲ្យទៅរុះផ្ទះនៅចំការដូងក៏ទៅដែរ ហើយផ្ទះសុទ្ធតែដើមត្នោតទៀតរុះហើយសុទ្ធតែរត់ទៀត(មានសំលេងកូនក្មេង) បើមិនអញ្ចឹងខ្លាចធ្លាក់មកងាប់ណាចេះតែធ្វើចេះតែទាញទៅអាងតែខ្លាចគេ ហើយឈើធំៗណាស់មិនតូចៗអញ្ជឹងទេណាកូនណា(ស្តាប់មិនបាន)អានាបគ្រែរ អានាបក្រាល(រនាបគ្រែរ រនាបក្រាល)អីចឹងណាថារុះអាមួយណាមុនឬក៏រុះអាស័ង្កសីមុនអញ្ជឹងទៅ រុះជញ្ជាំងមុនទៅបើថាមិចៗទេ ហែងរលំទៀតចាំ ឲ្យវាទៅៗ បន្ទាប់មកចាំរត់ចេញទៅណាកូនណា(មានសំលេងប្ញំខានពីខាងក្រៅ) វាមិនត្រោះថ្នាក់យើងយើងចេះតែតស៊ូទៅណាកូនណា ធ្វើមិចយើងចេះតែច្នៃប្រឌិតឲ្យតែនៅរស់សិនទៅណា កុំឲកយតែងាប់ខ្លួនណាគិតអញ្ជឹង(មានសំលេងរំខានពីខាងក្រៅ)!

ក៖ ចាសៗម៉ា(មានសំលេងរំខានពីខាងក្រៅ)!

ខ៖ អញ្ចឹងបានថាចូលមកសម័យអាពត( សម័យ ប៉ុល ពត) និង ជំលៀសចេញមកវិញដែលគេយក អាទះភ្លើង(រទេះភ្លើង)មកដឹកណាកូនណា ទៅៗបានទៅធ្វើស្រែធ្វើអីទៅ(មានសំលេងរំខានពីខាងក្រៅ)!

ក៖ ចុះកាលសម័យនិងម៉ាចងចាំទិដ្ឋភាពអីជាងគេទៅ(មានសំលេងកូនក្មេង)?

ខ៖ ហើយអត់មានចាំអីទេកូន និយាយថាក្រោកពីយប់ឲ្យតែព្រលឹមឡើង បើកភ្នែកវិញថារស់ៗហើយ ល្ងាចឡើងយប់ដល់ម៉ោងដេកៗទៅ ដឹងខ្លួនឡើងពេលភ្លឺហើយអឺបានរស់មួយយប់ទៀតហើយ!

ក៖ ម៉ាមានបន់ទេថាឲ្យឆាប់ផុតជំនាន់សម័យនិង(មានសំលេងរំខានពីខាងក្រៅ)?

ខ៖ ហើយទៅបន់ឯណាកូន(មានសំលេងរំខានពីខាងក្រៅ)បើមិនដឹងទិសដៅរកតែធូបរកតែទានមិនបានផងនោះអត់មានទេកូន!

ក៖ (សើច)!

ខ៖ អត់មានទេ!

ក៖ ក្រែងម៉ាមានបន់នៅក្នុងចិត្តអញ្ចឹងទៅណា?

ខ៖ ក្នុងចិត្តម៉ាចេះតែបន់ទៅ ឲ្យតែមានលោកណាមកជួយមិនភ្លេចគុណគេទេ និយាយត្រង់!

ក៖ ចាសម៉ា!

ខ៖ និយាយត្រង់ក្នុងចិត្តយើងប៉ងណា(មានសំលេងរំខានពីខាងក្រៅ)ដែលចិត្តយើងពិបាកពេកហ្មាំ និងហើយ ឲ្យតែអ្នកណាមានបុណ្យមកជួយអឺដឹងតែមិនភ្លេចគុណគេទេ!

ក៖ (មានសំលេងរំខានពីខាងក្រៅ)ចាសម៉ា អញ្ចឹងម៉ាមានធ្លាប់(ស្តាប់មិនបាន)ឆ្លងកាត់បទពិសោធន៍ច្រើនអញ្ចឹងម៉ាមានរឿងអ្វីដែលពិបាកជាងគេដែលធ្វើឲ្យម៉ាចងចាំមិនភ្លេចសោះឡើយមានទេម៉ា?

ខ៖ (មានសំលេងរំខានពីខាងក្រៅ) គឺដីធ្លីគេរករឿងម៉ាគេថាម៉ាយករបស់គេអញ្ចឹងណា តាមពិតទៅមករុះរើរបស់ខ្ញុំ ហើយយករបស់យើងទៀត ហើយខ្ញុំមិនព្រមតុលាការកាត់ឲ្យយើងឈ្នះហើយនិង

នៅទៅរករឿងយើងទៀត(មានសំលេងរំខានពីខាងក្រៅ)វាឲ្យយើងរំលាយចេញទៀតហើយធ្វើមិចរំលាយកើត បើតុលាការគេអ្នកកាត់ឲ្យខ្ញុំ ហើយខ្ញុំមានធ្វើអីទាល់តែសម្ដេចហ៊ុនសែនមកធ្វើអត្តាគមន៍ទើបចាប់ខ្ញុំបានដាក់គុក(ស្ដាប់មិនបាន)ហើយខ្ញុំដកពាក្យបណ្ដឹងមកវិញខ្ញុំក៏មានធម៌មេត្តាវាដឹងខ្លួនភ្ញាក់រលឹកហើយណា!

ក៖ អឺ....!

ខ៖ ដល់វាចេញពីគុកមកចង់ផ្ដឹងផ្ដល់យើងទៀតណា អាក្រក់ណាស់!

ក៖ បានអញ្ចឹងបានថាមនុស្សវាអាក្រក់ណាស់កូន ហើយខ្ញុំមានតែលក់ដីឲ្យវាឯណាផ្ទះខ្ញុំ(មានសំលេងរំខានពីខាងក្រៅ)ផ្ទះខ្ញុំអីខ្ញុំៗណាទៅលក់ដីឲ្យ!

ក៖ ចាសម៉ា!

ខ៖ មានតែហៅគេឲ្យមកនៅ(មានសំលេងរំខានពីខាងក្រៅ)គេទិញនិងប្រពន្ធក៏ធ្វើការរទេះភ្លើងដែរ(ស្ដាប់មិនបាន)ដល់ប្ដីឈឺស្លាប់ទៅក៏លក់ទៅណាដើម្បីទៅស្រុកអញ្ចឹងណាកូនណា(មានសំលេងរំខានពីខាងក្រៅ)នៅបែកចានហ៎ បានថាទិដ្ឋភាពនិងគឺចងចាំៗអារឿងវាធ្វើបាបនិងហើយអូសខ្ញុំទៅវៃទាំងគ្រួសារទាំងអស់កុំបានគេជួយទេណា!

ក៖ វេទនាណាស់ម៉ា(មានសំលេងរំខានពីខាងក្រៅ)!

ខ៖ ចាសកុំអីងាប់បាត់អស់ហើយ កុំបានគេជួយខ្ញុំទេខ្ញុំនិយាយឲ្យអស់និងខ្ញុំពិបាករាល់ថ្ងៃពិបាករឿងនិង(មានសំលេងរំខានពីខាងក្រៅ)តែកុំបានមេធាវីគេហៅសាក្សីអីមកជួយទេណាកូនណា
គេនៅតែអាណិតយើងណាគេជួយធ្វើសាក្សីធ្វើអីទៅមិនភ្លេចគុណគេទេ(មានសំលេងរំខានពីខាងក្រៅ)ហើយបានលោកជំទាវ ហូ យុតធី គាត់ជួយខ្ញុំទេណា
គ្រួសារខ្ញុំកុំអីងាប់គេយកទៅវៃងាប់អស់កូនណា
សាហាវណាស់នេះ(មានសំលេងរំខានពីខាងក្រៅ)!

ក៖ គាត់យកមិចទៅម៉ា?

ខ៖ គាត់ដូចថា
គាត់ឃើញវាអយុត្តិធម៌ពេកណាគាត់ជួយគាត់បានធ្វើពាក្យបណ្ដឹងអីឲ្យយើងណាកូនណា !

កៈ ចាសម៉ា(មានសំលេងរំខានពីខាងក្រៅ)!

ខៈ និងហើយបានគុណគាត់មិនភ្លេចគុណគាត់ទេកូនអញ្ចឹងបាបថា!

កៈ ប៉ុន្តែមុននិងគេអូសយកទៅវៃតែម្តងណំម៉ា?

ខៈ អូសយកទៅវៃក្នុងផ្ទះវាន់ វាថាយើងទៅរករឿងវាវាបាញ់និងទឹកថ្នាំវាបាញ់និងអាស៊ីយូ(ទុយោ)លាងទឹកលាងអីនិង ណាកូនណាបាញ់ឡើងទុនខ្លួនមីកូនខ្ញុំមីមួយនោះឡើងគ្នាហ៊ាឈាមតាមច្រមុះមីមួយឡើងសន្លប់អូសបីនាក់យកទៅវៃក្នុងផ្ទះវា!

កៈ ដោយសាតែរឿងដីហំម៉ា?

ខៈ ដោយសារតែរឿងដីៗនៅរាល់ថ្ងៃនិងខ្ញុំជំរាបកូនឯត្រង់តែម្តងឲ្យគេមើលឃើញចុះការពិតអ៊ឹអត់ខ្លាចទេ(មានសំលេងរំខាននៅខាងក្រៅ)!

កៈ ចាសម៉ាតែដីនិងមានប្លង់រឹងអីដែរទេ?

ខៈ ដីប្លង់ មានអស់ហើយនិងកូន ឥលូវធ្វើប្លង់ធ្វើអីអស់ហើយនៅវាមករករឿងទៀតវាឲ្យរំលាយកិច្ចព្រមព្រាងនរណារំលាយ(មានសំលេងរំខានពីខាងក្រៅ)ព្រោះខ្ញុំមិនបានបង្កើតខ្លួនឯងឯណាគឺច្បាប់ណាអ្នកបង្កើត!

កៈ ចាសម៉ា (មានសំលេងរំខានពីខាងក្រៅ)!

ខៈចាសខ្ញុំនិយាយសុទ្ធតែរឿងពិតទាំងអស់(មានសំលេងរំខានពីខាងក្រៅ) ហើយប្រពន្ធវាមកសុំអង្វរឲ្យដកពាក្យបណ្តឹងទៅសុខចិត្តជួយ ដូចថាដល់រួចទៅឲ្យដីឲ្យធ្លីខ្ញុំវិញណា និងហើយ(មានសំលេងរំខានពីខាងក្រៅ)ហើយឲ្យប្រាក់បង់ដែលវាទៅវៃកូនខ្ញុំអីណា ហើយកូនឯងមើលបានថាមនុស្សឥលូវអាក្រក់ណាស់កូនអាក្រក់ជាងមុនឆ្ងាយណាស់មែនណា!

កៈ អឺ...ចាស!

ខៈ ខ្ញុំឆ្អែតត្រង់និងតើនិងកុំបានគេជួយខ្ញុំផងកុំអីមិនដឹងទៅជាស្អីបែបងាប់អស់ហើយកូនខ្ញុំ(មានសំ

លេងរំខានពីខាងក្រៅ)និងបានថាចប់ទៅខ្ញុំឈឺចាប់និងរឿងនិងខ្ញុំមិនដែលធ្វើអាក្រក់ដាក់នរណាទេ!

ក៖ អឺ...!

ខ៖ ជំនាន់អាពត(ជំនាន់ ប៉ុល ពត) ក៏គេឲ្យទានខ្ញុំស៊ីខ្ញុំមិនភ្លេចគុណគេទេកូន!

ក៖ ចាសម៉ា!

ខ៖ មកនេះនែកមិកចេញពីទន្លេរសាបទៅ(មានសំលេងរំខានពីខាងក្រៅ)ប៉ុន្តែរឥលូវគាត់ស្លាប់ហើយនៅតែប្រពន្ធទេប្រពន្ធឈ្មោះ យឺងហើយគាត់ ឈ្មោះ តៃ លី (មានសំលេងរំខានពីខាងក្រៅ)មិនថាមិចទេក្មួយឯងសួរមកខ្ញុំនិយាយសុទ្ធតែជាការពិតទាំងអស់ មិនកុហកទេ កូនគាត់នោះឈ្មោះអាយាហើយមួយទៀយនោះខ្ញុំភ្លេចឈ្មោះបាត់ហើយយូរដែរហើយណាកូនណា(មានសំលេងរំខានពីខាងក្រៅ)យូរណាស់ភ្លេចឈ្មោះអស់ហើយចាំតែអាយាមួយប្រុសស្រីមិនដឹងឈ្មោះអីទៀតទេ!

ក៖ ហើយគេអ្នកចង់បានដីអ៊ុំនិងគាត់ត្រូវជាយ៉ាងមិចដែរ?

ខ៖ ជាអ្នកដទៃមកទិញដីនិងវាលោភលន់វាចង់បាន(មានសំលេងរំខានពីខាងក្រៅ)វាឃើញរបស់យើងនិងធ្វើបាបអ្នកស្លូតត្រង់ណាកូនណា!

ក៖ ចាសម៉ា!

ខ៖ វាស្ទាត់វាចេះតែធ្វើបាបយើងទៅ(មានសំលេងរំខានពីខាងក្រៅ)!

ក៖ (មានសំលេងរំខានពីខាងក្រៅ) ដល់ឥលូវគាត់ត្រូវច្បាប់ដាក់ទោសគាត់ទេម៉ា?

ខ៖ ដាក់ទោសនិងហើយដែលដកពាក្យបណ្តឹងនិងចេញ ដល់ឥលូវវាមករករឿងយើងវិញ!

ក៖ (មានសំលេងរំខានពីខាងក្រៅ)អឺ....!

ខ៖ វាមករករឿងយើងវិញវាប៉ុន្មានឆ្នាំហើយនិង(មានសំលេងរំខានពីខាងក្រៅ)ប្រហែលជិត១០ឆ្នាំហើយនិង!

ក៖ ដល់មានរឿងអញ្ចឹង(មានសំលេងរំខានពីខាងក្រៅ)តែជាមួយគ្រួសារម៉ាទេហ៎?

ខ៖
ចាសវាចេះតែរករឿងយើងទៅហើយយើងក៏កុំតជាមួយវា(មានសំលេងរំខានពីខាងក្រៅ)បើគេហៅទៅណាច្បាប់គេមកហៅយើងចេះតែទៅៗហើយយើងនិយាយតែការពិតទេណាកូនណា!

ក៖ ចាសម៉ា!

ខ៖ និងហើយសង្កាត់អីមកហៅនិយាយតែការពិតនិងទៅ!

ក៖ អញ្ចឹងជីវិតរបស់ម៉ាមានតែរឿងមិនមួយទេន៎?

ខ៖ ចាស មានតែការឈឺចាប់និងមួយទេកូននិយាយទៅរាល់ដងអ៊ុំមិនដែលធ្វើអីអាក្រក់ទេ គេថាសុំត្រឹមជីវិតមួយរស់បានដូចគេដូចឯងទៅបានហូបបាន ចុកអីបរបូរដូចគ្នាទៅណាកូនណា អត់មានអីទៀតទេ បើយើងចេះតែធ្វើទៅចេះតែរកទៅចេះតែបានទៅ ណាកូនណាតែវាមកឈឈចាប់និងអារឿងប៉ុណ្ណឹងៗ(មានសំលេងរំខានពីខាងក្រៅ) ដូចថាវាមិនដឹងខុសដឹងត្រូវវាប្រមាថកាត់ទៀនមកលើយើងណា!

ក៖ ចាសម៉ា(មានសំលេងរំខានពីខាងក្រៅ)!

ខ៖ អញ្ចឹងបានថាមានតែប៉ុណ្ណឹងទេកូន!

ក៖ ចុះសំរាប់បទពិសោធន៍ជីវិតរបស់ម៉ាល្អៗវិញមានអ្វីខ្លះ(មានសំលេងរំខានពីខាងក្រៅ)?

ខ៖ រឿងល្អៗមិនមានស្អីទេកូន(មានសំលេងរំខានក្រៅ)មានដូចថាយើងសាងតែអំពើរល្អទៅ ធ្វើតែល្អដាក់អ្នកជិតខាងទៅ បើទៅកន្លែងនិងអញ្ចឹងបើគេមិនឲ្យអ្នកផ្សេងគេដឹងគរឲ្យទានអញ្ចឹងទៅណាកូនណា យើងយកព្រះពុទ្ធសាសនាយកមកដាក់ក្នុងខ្លួនណា!

ក៖ ចាសម៉ា!

ខ៖ យកធម៌ព្រះមកដាក់ក្នុងខ្លួន(មានសំលេងរំខានពីខាងក្រៅ) បន្ទាបើមកយើងធ្វើតែអំពើរល្អហើយអំពើរអាក្រក់កុំធ្វើទៅ(មានសំលេងរំខានពីខាងក្រៅ)ធ្វើអីឲ្យខុសពីនិងទៅ(ស្តាប់មិនបាន)!

កៈ ម៉ាអញ្ចឹងចំពោះមតិចុងក្រោយ(មានសំលេងរំខានពីខាងក្រៅ) ឬសំណូមពរដែលចជាពាក្យពេចន៍ចុងក្រោយរបស់អ៊ុំដែលអ៊ុំចង់ផ្តាំផ្ញើរជាពិសេសកូនចៅរបស់អ៊ុំជំនាន់ក្រោយដែលគេបានស្តាប់សំលេងនេះ(មានសំលេងរំខាននៅក្រៅ)!

ខៈ ឆ្លើយថាមិច(មានសំលេងរំខានពីខាងក្រៅ)!

កៈ
អ៊ុំមានពាក្យអីដើម្បីនិយាយជាចុងក្រោយនៅក្នុងការយកដាក់ដូចជាពាក្យពេចន៍ដែលអ៊ុំចង់ផ្តាំផ្ញើរទៅដល់អ្នកដែលគេបានស្តាប់និងកូនចៅ(មានសំលេងរំខានពីខាងក្រៅ)ដូចជាកូចចៅអ៊ុំដែលគេបានស្តាប់សំលេងរបស់អ៊ុំអញ្ចឹងណា?

ខៈ អត់មានពាក្យអីទេ(មានសំលេងរំខានពីខាងក្រៅ) សុំឲ្យតែកូនចៅបានសុខសប្បាយទៅឲ្យប្រទេស ជាតិយើងរុងរឿងទៅណាកូនណា ឲ្យតែស្រុកខ្មែរយើងបរបូរហ៊ាហូរទៅ
ថាធ្វើមិចធ្វើទៅឲ្យតែបានសុខ(មានសំលេងរំខានពីខាងក្រៅ)កុំឲ្យជួបទុក្ខវេទនាទៀតណាកូនណាម៉ា សុំតែប៉ុណ្ណឹងទេ
ហើយកូនចៅយើងបានការងារធ្វើទៅគ្រាន់បានហូបចុកដូចគេដូចឯងទៅណាឲ្យអ៊ុំទៅធ្វមិចទៀត!

កៈ ចាសម៉ា!

ខៈ និងហើយសុំតែប៉ុណ្ណឹងទេសុំឲ្យបានតែប៉ុណ្ណឹងទេណាកូនណា!

កៈ ចាសៗម៉ា!

ខៈ សុំឲ្យបរបូរហ៊ាហូរទៅ(មានសំលេងរំខានពីខាងក្រៅ)សុំឲ្យប្រជាជនចេះស្រលាញ់គ្នាឡើងទៅណាកូន ចេះអប់រំគ្នាទៅណាកូនដូចថាយើងចេះតែដើរតាមទៅចិត្តយើងសមស្រប ហើយយើងចេះតែធ្វើតាមទៅកាលណាមិនសមស្រប យើងកុំទៅជិតគេកូន!

កៈ អឺ….!

ខៈ ម៉ានិយាយអញ្ចឹងខុសក៏ត្រូវកូន?

កៈ ចាសត្រូវម៉ា(មានសំលេងរំខានពីខាងក្រៅ)!

ខៈ គ្រាន់តែប៉ុណ្ណឹងអត់មានស្អីទៀតទេ បើនិយាយវាវែងឆ្ងាយទៀតណាកូនណា!

កៈ ចាសម៉ា!

ខៈ ឲ្យតែអំពើរណាដែលល្អយើងយកដាក់ខ្លួនទៅ ហើយអំពើរណាដែលល្អយើងគេចចេញទៅ!

កៈ ចាសម៉ា!

ខៈ សុំតែប៉ុណ្ណឹងទេអត់មានអីទៀតទេកូន!

កៈ ចាសម៉ា!

ខៈ ឲ្យកូនចៅបានល្អទាំងគ្នា!

កៈ ចាសម៉ា!

ខៈ (ស្តាប់មិនបាន)បែបអស់ហើយកូន(មានសំលេងរំខានពីខាងក្រៅ)នៅតិចណាស់កូនធ្វើមិចឲ្យចេះស្រលាញ់គ្នាអប់រំគ្នាទៅវិញទៅមកទៅណាកូនណា!

កៈ ចាសម៉ា!

ខៈ សាងតែអំពើរល្អដាក់គ្នាទៅ!

កៈ ចាសម៉ា!

ខៈ អញ្ចឹងបានថា មានតែប៉ុណ្ណឹងអត់មានស្អីទៀតទេ!

កៈ ចាសម៉ា!

ខៈ អឺ...!

កៈ អគុណច្រើនម៉ាសំរាប់ដែលផ្តល់ពេលវេលានិងផ្តល់ពេលដើម្បីឲ្យចៅដើម្បីសម្ភាសន៍ម៉ាផ្ទាល់!

ខៈ ចាសកូន!

កៈ នៅជីវប្រវត្តិរបស់ម៉ា!

ខៈ អឺ....!

កៈ ហើយនិង(មានសំលេងរំខានពីខាងក្រៅ)និងជិវិតនៃការតស៊ូ!

ខៈ ចាសកូន!

កៈ
តាំងពីមុនមកដល់ឥលូវអញ្ចឹងម៉ាអាចអនុញ្ញាតិឲ្យថៅយកសំលេងនេះយកទៅដាក់នៅវែបសាយ ដើម្បីឲ្យគេបានស្តាប់ដែរទេ?

ខៈ
ចាសធ្វើមិចធ្វើទៅកូន(មានសំលេងរំខានពីខាងក្រៅ)ព្រោះអ៊ុំនិយាយសុទ្ធតែពាក្យពិតពាក្យល្អទាំងអស់បើកូនយកទៅផ្សាយទៅឲ្យពិភពលោកគេបានដឹងលឺទាំងអស់ក៏ល្អដែរណាកូនណា!

កៈ ចាសម៉ា!

ខៈ
ព្រោះអ៊ុំអត់និយាយពីបញ្ហាអីផ្សេងទេអ៊ុំនិយាយតែពីប្រវត្តិរបស់អ៊ុំតើ(មានសំលេងរំខានពីខាងក្រៅ)

គៈ ការ៉េមកីផ្អែមត្រជាក់ចិត្ត!

កៈ ចាសម៉ា!

ខៈ មានតែប៉ុណ្ណឹងទេ!

កៈ ចាសអគុណម៉ា ជំរាបលាម៉ា!

ខៈ ចាសកូន!

កៈ សង្ឃឹមថានិងជូនពរឲ្យម៉ាមានសុខភាពល្អ!

ខៈ ចាសកូន!

កៈ និងក្រុនគ្រួសារមានសុភមង្គល!

ខៈ ចាសកូនចាស!

កៈ ចាសអគុណ!

គៈ ការ៉េមកីផ្អែមត្រជាក់ចិត្ត(មានសំលេងរំខានពីខាងក្រៅ)!